

# ភ្លើង! កាមេរ៉ា! ចាប់ផ្ដើម!

The Asia Foundation - Let’s Read,
Tassaya (Toffy) Charupatanapongse

Let’s Read
The Asia Foundation



ឆាយ៉ាមិនដឹងថាត្រូវពាក់ស្រោមជើងមួយគូណាឡើយព្រឹកនេះ។ នាងក៏បិទភ្នែករើសដោយព្រាវ។ នាងក៏ចាប់បានស្រោមជើងរូបទន្សាយរបស់ប្អូនស្រីនាង។ «ពិតជាគួរឱ្យខ្មាសគេណាស់។ សង្ឃឹមថាគ្មាននរណាម្នាក់ចាប់អារម្មណ៍ទៅចុះ!»



ទៅដល់ក្នុងថ្នាក់ ឆាយ៉ាដាក់ជើងនៅក្រោមតុដើម្បីកុំឱ្យអ្នកណាមើលឃើញ។ អ្នកគ្រូ សាន មកដល់ ទះដៃជាសញ្ញា។ «ល្អណាស់កូនៗ! អង្គុយចុះ! ថ្ងៃនេះអ្នកគ្រូមានកិច្ចការថ្មីទាក់ទងនឹងការធ្វើរបាយការណ៍សម្រាប់កូនៗ។» ឆាយ៉ាអង្គុយចុះយ៉ាងអន្ទះសា។ នាងចូលចិត្តស្វែងរកប្រធានបទរបាយការណ៍ថ្មីៗ ការស្រាវជ្រាវ និងកិច្ចការសំណេរ។ អ្នកគ្រូ សាន បន្តទៀតថា «កិច្ចការយើងសប្តាហ៍នេះប្លែកពីមុន។ យើងនឹងថតជាវីដេអូខ្លីជំនួសរបាយការណ៍។ កូនៗនឹងបានរៀនធ្វើជាអ្នកផលិតកម្មវិធី។»



ឆាយ៉ានិងមិត្តរួមថ្នាក់ រំភើបយ៉ាងខ្លាំងព្រោះពួកគេមិនធ្លាប់ថតវីដេអូទេ! សិស្សម្នាក់ក៏សួរ៖ «តើប្រធានបទអ្វីទៅអ្នកគ្រូ?» អ្នកគ្រូសានតបដោយសរសេរប្រធានបទលើក្តារខៀន «តើប្អូនអាចរួមចំណែកកែលម្អសាលារៀនបានតាមរបៀបណា?» «កូនៗត្រូវមានភាពច្នៃប្រឌិត! ជ្រើសរើសអ្វីដែលកូនៗគិតថាសំខាន់បំផុត ហើយបញ្ជាក់ពីហេតុផល!»



ភ្លាមនោះ សិស្សក្នុងថ្នាក់ចាប់ផ្ដើមចែករំលែកគំនិតគ្នារៀងៗខ្លួន។ មិត្តម្នាក់និយាយ៖ «ខ្ញុំនឹងនិយាយពី មូលហេតុដែលយើងមិនគួរស្លៀកឯកសណ្ឋាននៅសាលារៀន។» មិត្តម្នាក់ទៀតបន្ថែម «ខ្ញុំនឹងលើកពីមូលហេតុដែលយើងត្រូវញ៉ាំទឹកដោះគោរៀងរាល់ថ្ងៃ!»។



ឆាយ៉ាស្ដាប់មិត្តរបស់នាងរៀបរាប់ពីគំនិតរបស់ពួកគេ។
មានគំនិតច្រើនណាស់! តើឆាយ៉ានឹងសម្រេចចិត្តយ៉ាងណា?



ពេលចេញទៅផ្ទះ ឆាយ៉ាចេញពីថ្នាក់ក្រោយគេ។ នាងប្រាប់អ្នកគ្រូសាន៖ «ខ្ញុំចង់ថតវីដេអូណាស់អ្នកគ្រូ ប៉ុន្តែគំនិតច្រើនពេក ខ្ញុំមិនដឹងថាត្រូវយកមួយណាទេ»។ អ្នកគ្រូសានតបវិញ៖ «មានគំនិតស្រាប់គឺល្អហើយ មានន័យថាកូនមានអ្វីជាច្រើនដែលត្រូវនិយាយ! សាកគិតថា កូនជាអ្នកផលិតកម្មវិធីម្នាក់ ដូច្នេះតើនរណាខ្លះជាអ្នកមើលកម្មវិធីរបស់កូន?»



ឆាយ៉ានិយាយ៖ «គឺអ្នកគ្រូ និងមិត្តរួមថ្នាក់។» អ្នកគ្រូសាន ញញឹម រួចតបថា៖ «ត្រឹមត្រូវហើយ! តើអ្វីទៅដែលគួរឱ្យចាប់អារម្មណ៍សម្រាប់ពួកយើង និងកូនខ្លួនឯងផងនោះ?» ឆាយ៉ានិយាយលេង៖ «ប្រហែលជា អ្នកគ្រូអាចដាក់កិច្ចការផ្ទះឱ្យពួកយើងតិចជាងមុន!»



អ្នកគ្រូសានញញឹមដោយយល់ស្រប ព្រោះមានន័យថា គាត់មិនសូវចំណាយពេលច្រើនក្នុងការកែកិច្ចការ! ប៉ុន្តែគាត់យល់ថា ឆាយ៉ាត្រូវតែគិតឱ្យបានដិតដល់ពីប្រធានបទ។ បន្ទាប់មក អ្នកគ្រូសានក៏រំឭក ឆាយ៉ាថា អ្នកផលិតកម្មវិធីល្អ គឺដូចអ្នកសរសេររបាយការណ៍ល្អដែរ។ ឆាយ៉ាត្រូវបង្ហាញពីគំនិតសំខាន់មួយ និងខ្លឹមសារលម្អិតដែលគាំទ្រគំនិតសំខាន់នោះ។



ល្ងាចឡើង ឆាយ៉ាដើរក្នុងភូមិដើម្បីគិតពីគម្រោងរបស់នាង។ នាងចូលចិត្តស្រង់ក្លិនអាហារដ៏ឈ្ងុយឆ្ងាញ់ដែលអ្នកជិតខាងនាងចម្អិនសម្រាប់ពេលល្ងាច។ នាងបានចូលលេងផ្ទះមិត្តម្នាក់ឈ្មោះ លីណា។ ឆាយ៉ាសួរ៖ «តើឯងនឹងថតវីដេអូអំពីអ្វីដែរ?» លីណាតប៖ «ខ្ញុំគិតថា សាលាគួរចែកអាហារសម្រន់ឱ្យសិស្សញ៉ាំមុនពេលចូលរៀន។»



ឆាយ៉ាចង់នឹកឱ្យឃើញគំនិតណាមួយ។ លីណាបន្ត៖ «ខ្ញុំបារម្ភព្រោះខ្ញុំអត់មានម៉ាស៊ីនថតទំនើបទេ។ ប៉ុន្តែក្រោយមក ម៉ែប្រាប់ថាកិច្ចការនេះផ្តោតលើសាច់រឿង សំខាន់ជាងឧបករណ៍។ ដូច្នេះខ្ញុំអាចប្រើទូរសព្ទគាត់ថតវីដេអូបាន។» ឆាយ៉ាមិនទាន់បានគិតពីការថតវីដេអូនៅឡើយទេ! នាងត្រូវរកគំនិតឱ្យបានលឿនបំផុត។



ថ្ងៃបន្ទាប់ ឆាយ៉ានៅតែបារម្ភពីរឿងដែលនាងត្រូវធ្វើសម្រាប់វីដេអូនាង។ ក្នុងទីធ្លាសាលា លោកគ្រូអ្នកគ្រូមើលសិស្សានុសិស្សកំពុងលេងរត់ដេញចាប់។ ពួកគេសើចក្អាកក្អាយ និងរត់ចុះឡើងមុនចូលរៀន។ ឆាយ៉ាសម្លឹងមើល និងគិតដល់ពួកគេ ដែលជាចំណែកសំខាន់ក្នុងសាសារៀននេះ។



សុធី ជាមិត្តរបស់ ឆាយ៉ាក៏ចូលមកអង្គុយជាមួយនាង។ ឆាយ៉ាក៏សួរ៖ «តើឯងនឹងថតវីដេអូអំពីអ្វី?» សុធីឆ្លើយទាំងរីករាយ៖ «ខ្ញុំចង់ឱ្យសិស្សសាលាយើងមានកុំព្យូទ័រប្រើម្នាក់មួយ!»



សុធីបន្តទៀត៖ «ខ្ញុំបានគិតពីគម្រោងនេះជាមួយប៉ាខ្ញុំពីយប់មិញ។ យើងបានកត់ត្រាពីទីកន្លែង និងអ្វីដែលខ្ញុំត្រូវថតសម្រាប់ផ្នែកនីមួយៗ។ ស្អែកនេះខ្ញុំនឹងចាប់ផ្ដើមតែម្ដង!» វីវរហើយ! ឆាយ៉ាមិនទាន់បានគិតពីគម្រោងប្លង់វីដេអូរបស់នាងនៅឡើយ។ នាងនៅតែគិតមិនទាន់ចេញថាត្រូវសរសេរពីអ្វីផង!



នារសៀលនោះ អ្នកគ្រូសានសង្កេតឃើញឆាយ៉ាមានទឹកមុខស្រពោន។ ឆាយ៉ាពោល៖ «ខ្ញុំមានកិច្ចការច្រើនណាស់ដែលត្រូវធ្វើ។ ខ្ញុំត្រូវរៀបប្លង់ថត និងខ្ចីទូរសព្ទម៉ាក់ខ្ញុំដើម្បីថតវីដេអូ។» អ្នកគ្រូសាននិយាយ «កូនក៏អាចប្រើទូរសព្ទដៃនោះ សម្រាប់កាត់តវីដេអូផងដែរ។» «កាត់ត! ខ្ញុំក៏មិនទាន់គិតពីចំណុចនេះដែរ! ឥឡូវនេះខ្ញុំនៅមិនទាន់រកគំនិតឃើញផង!»



តាមផ្លូវទៅផ្ទះវិញ ឆាយ៉ាតាំងចិត្តថា ត្រូវតែរើសយកគំនិតមួយឱ្យបាន។ នាង មើលទៅមិត្តភក្តិដែលកំពុងដើរជិតនាង លោកគ្រូអ្នកគ្រូកំពុងបក់ដៃ និងផ្សែងហុយពីចង្ក្រាន។ គំនិតមួយក៏បានផុសឡើង! ពេលនេះ ឆាយ៉ាដឹងច្បាស់ថានាងត្រូវធ្វើអ្វីហើយ។







ល្ងាចនោះ ឆាយ៉ាក៏ចាប់ផ្ដើមរៀបចំគំនិតរបស់នាង។ បន្ទាប់មក
នាងបានខ្ចីទូរសព្ទម៉ាក់នាង និងទៅសម្ភាសអ្នកជិតខាង។



ថ្ងៃបន្ទាប់ នាងបានកាត់តវីដេអូនោះក្នុងទូរសព្ទដៃ ជាមួយម៉ាក់របស់នាង ប្រៀបដូចអ្នកផលិតកម្មវិធីមែនទែនអ៊ីចឹង!



ទីបំផុត ថ្ងៃដែលសិស្សទាំងអស់ត្រូវបង្ហាញវីដេអូបានមកដល់ ហើយក៏ដល់វេន ឆាយ៉ាត្រូវបង្ហាញវីដេអូរបស់នាងដល់មិត្តរួមថ្នាក់ហើយ។ ឆាយ៉ាចុចប៊ូតុងចាក់វីដេអូដោយក្ដីបារម្ភ។



ដំបូង វីដេអូនោះ បង្ហាញពីមិត្តភក្តិ លោកគ្រូអ្នកគ្រូ និង
អ្នកជិតខាងរបស់នាង។ បន្ទាប់មក វាបង្ហាញពីអាហារឆ្ងាញ់ៗ
យ៉ាងច្រើន! «ខ្ញុំនឹងចូលរួមកែលម្អសាលារៀនយើង តាមរយៈ
មុខម្ហូបដែលមានអត្ថន័យសម្រាប់ពួកយើងម្នាក់ៗ។ យើងគួរ
មានកម្មវិធីជប់លៀងក្នុងសាលារៀន ដែលម្នាក់ៗយកអាហារ
ដែលខ្លួនចូលចិត្តមកញ៉ាំជុំគ្នា!» វីដេអូរបស់ឆាយ៉ាបង្ហាញពី
ការបង្កើតសហគមន៍ដ៏រឹងមាំមួយដោយការអញ្ជើញលោក
គ្រូអ្នកគ្រូ សិស្សានុសិស្ស និងក្រុមគ្រួសារពួកគេ ព្រមទាំង
អ្នកជិតខាងទាំងអស់មកញ៉ាំអាហារប្រកបដោយភាពរីករាយ។



សិស្សក្នុងថ្នាក់ទះដៃ ឯអ្នកគ្រូសានវិញ ញញឹមរួចនិយាយ៖ «អស្ចារ្យណាស់ ឆាយ៉ា!» គ្រប់គ្នាទទួលស្គាល់ថា នេះជាគំនិតដ៏ល្អ ហើយពួកគេក៏ឃ្លានល្មម! អ្នកគ្រូសានញាក់ភ្នែកជាសញ្ញា រួចនិយាយ៖ «អ្នកគ្រូយល់ថា យើងត្រូវកំណត់ថ្ងៃរៀបចំពិធីជប់លៀងក្នុងសាលាម្តងហើយ។»



ឆាយ៉ាញញឹម។ នាងសប្បាយចិត្តណាស់ដែលនាងអាច ធ្វើឱ្យគេជឿលើគំនិតរបស់នាង។ នាងក៏បានគិតពីប្រធានបទបន្ទាប់ដែលនាងត្រូវធ្វើផងដែរ។

Generously supported by Smart Axiata

អនុញ្ញាតឱ្យប្រើប្រាស់ដោយ ក្រសួងអប់រំ យុវជន និងកីឡា

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*ភ្លើង! កាមេរ៉ា! ចាប់ផ្ដើម! (Lights! Camera! Action!)*, Author: The Asia Foundation - Let's Read, Tassaya (Toffy) Charupatanapongse. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC-BY-NC-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-NC-4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/